# ការប្រើប្រាស់ កាតសំរាប់មនុស្សចាស់

**បញ្ចូលលុយនៅលើកាតរបស់អ្នក។ បន្ទាប់មកគ្រាន់តែប៉ះ ហើយឡើងជិះបាន!**




## ចាប់ផ្តើម

### 1. វិធីបញ្ចូលលុយនៅលើកាតរបស់អ្នក៖

- ចូលទៅកាន់ **myhopcard.com** ឬប្រើកម្មវិធីក្នុងទូរស័ព្ទ Hop Fastpass®
- ទូរស័ព្ទទៅលេខ **1-844-694-6722**
- ទិញតាមម៉ាស៊ីនលក់កាត Hop នៅស្ថានីយ៍ MAX និង WES
- បន្ថែមលុយក្នុងកាតនៅតាមហាងលក់ម្ហូប និងហាងលក់ទំនិញក្នុងស្រុករាប់រយកន្លែង

នៅពេលដែលអ្នកចុះឈ្មោះទិញកាតរបស់អ្នកនៅ **myhopcard.com** ចំនួនទឹកប្រាក់សរុបរបស់អ្នកត្រូវបានការពារ ប្រសិនបើ បាត់កាតរបស់អ្នក ឬកាតអ្នកត្រូវបានគេលួច។

### 2. យកកាតរបស់អ្នកទៅប៉ះលើម៉ាសីន Hop ដែលមានពណ៌បៃតង រាល់ពេលដែលអ្នកឡើងជិះ ឬប្តូរឡានក្រុងរឺរថភ្លើង។

- ពេលប៉ះគិតលុយដំបូងរបស់អ្នក អ្នកនឹងត្រូវបានគិតប្រាក់ $1.40 ហើយអ្នកអាចជិះបាន 2½ ម៉ោង។
- ប្រសិនបើអ្នកប្រើកាតប៉ះម្តងទៀតបន្ទាប់ពី 2½ ម៉ោង អ្នកនឹងត្រូវគិតថ្លៃម្តងទៀតចំនួន $1.40 ប៉ុន្តែថ្លៃសំបុត្រថ្មីរបស់អ្នក នឹងប្រើបានសម្រាប់ពេញមួយថ្ងៃ (អ្នកទទួលបានសំបុត្រមួយថ្ងៃពេញ)។
- អ្នកនឹងមិនត្រូវបានគេគិតប្រាក់រាល់ពេលដែលអ្នកប៉ះនោះទេ ប៉ុន្តែការប៉ះរបស់អ្នកគឺជាភស្តុតាងនៃចេញថ្លៃជិះរបស់អ្នក។
- ប្រសិនបើអ្នកកំពុងប្រើប្រាស់សំបុត្រសំរាប់មនុស្សចាស់ អ្នកអាចប្រើកាត Hop ដែលមានរូបថតរបស់អ្នកជាភស្តុតាងនៃសិទ្ធិទទួលបានការចុះតម្លៃ។

ដើម្បីទទួលបានជំនួយ ឬរាយការណ៍អំពីកាតដែលបាត់ សូមផ្ញើអ៊ីមែលទៅ **help@myhopcard.com** ឬទូរស័ព្ទទៅ **1-844-694-6722** ។

---

ដើម្បីស្វែងយល់បន្ថែម សូមចូលមើល
**trimet.org/hopcard**

TRIMET
How life moves®

240636 • 1/25